គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

(ADB TA 7305-CAM)





# ឯកសារបណ្តុះបណ្តាល

ស្តីអំពី

# ការពង្រឹងសមត្ថភាពក្រុមកសិករផលិត និង ជំនួញស្រូវពូជ



វិច្ឆិកា ២០១១

(DRAFT)

# មាតិកា


| ល.រ | មាតិកា | ទំព័រ |
|---|---|---|
| | **អារម្ភកថា** | ២ |
| ១ | ការបង្កើត និង កសាងក្រុម | ៣ |
| ២ | ការប្រាស្រ័យទាក់ទង | ៩ |
| ៣ | ការរៀបចំអង្គប្រជុំ | ១៣ |
| ៤ | ការសរសេ របាយការណ៍ និង កំណត់ហេតុ | ១៥ |
| ៥ | ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ | ២០ |
| ៦ | ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុម | ២៥ |
| ៧ | មូលដ្ឋានគ្រឹះទីផ្សារ | ២៩ |
| ៨ | ការចាប់ផ្តើមអាជីវកម្ម | ៣២ |
| ៩ | ការគ្រប់គ្រងអាជីវកម្ម | ៣៦ |
| ១០ | ការលើកកំពស់អាជីវកម្ម | ៤០ |
| ១១ | និរន្តរភាពអាជីវកម្ម | ៤៣ |


**ឯកសារយោង**


1. ការគ្រប់គ្រងសមាគមអាជីវកម្មធុនតូច រៀបចំដោយ អង្គការពលកម្មអន្តរជាតិ ឆ្នាំ ២០០៧
2. សៀវភៅមគ្គុទេសបណ្តុះបណ្តាលគ្រូបង្គោលសំរាប់ការអភិវឌ្ឍន៍ រៀបចំដោយអង្គការលូថេរ៉ាន បំរើពិភពលោក ឆ្នាំ ២០០៥
3. ចាប់ផ្តើម និង ការកែលំអរអាជីវកម្មរបស់អ្នករៀបចំអង្គការលូថេរ៉ានបំរើពិភពលោក ឆ្នាំ ២០០៧
4. អង្គការ FAO សៀវភៅធនធានសម្រាប់អន្តរក្រុមៈ ការណែនាំសម្រាប់បង្កើតសមាគមកសិករតូចៗ និងបណ្តាញការងារ

# អារម្ភកថា

គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD) ជាគម្រោងជំនួយបច្ចេកទេសដែលផ្តល់សហ–ហិរញ្ញប្បទានឥតសំណង សម្រាប់អនុវត្តដោយ រដ្ឋាភិបាលហ្វាំងឡង់ មូលនិធិជៃគូអ៊ី–អាស៊ី និងចែករំលែកពុទ្ធិនៃសាធារណៈរដ្ឋកូរ៉េ និង ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ រាជរដ្ឋាភិបាលកម្ពុជាចូលរួមបដិភាគមិនមែនជាថិកា (ធនធានមនុស្ស ការិយាល័យបំពេញការងារ...) សម្រាប់អនុវត្តគម្រោង។ ធនាគារអភិវឌ្ឍន៍អាស៊ី ជាអ្នកចាត់ចែងប្រតិបត្តិការផ្ទាល់ជំនួសមុខឱ្យម្ចាស់ជំនួយ។ គម្រោង បានធ្វើការសាកល្បងបង្ហាញបច្ចេកវិទ្យាកសិកម្ម និង ផ្តល់សេវាព័ត៌មានជនបទ ដើម្បីបង្កើន និងពង្រីកប្រាក់ចំណូលរបស់គ្រួសារកសិករខ្នាតតូចក្នុងខេត្ត កំពង់ចាម កំពង់ធំ សៀមរាប និង បន្ទាយមានជ័យ។

ឯកសារបណ្តុះបណ្តាលស្តីពី *ការពង្រឹងក្រុមកសិករផលិតស្រូវពូជលក់* នេះត្រូវបានរៀបចំចងក្រងឡើងដោយផ្អែកលើឯកសារយោងនានា ព្រមទាំងបទពិសោធន៍ល្អជាក់ស្តែងរបស់អ្នកអនុវត្តផ្ទាល់ ក្នុងគោលបំណងចងក្រងជាបង្គុំឯកសារជំនួយស្មារតី និងពង្រឹងនូវសមត្ថភាពដល់ក្រុមកសិករអាជីវកម្ម នៅតាមសហគមន៍ឱ្យទទួលបាននូវគំនិតសម្រាប់អភិវឌ្ឍន៍អាជីវកម្មរបស់ពួកគាត់ ឱ្យកាន់តែប្រសើឡើង។ ការធ្វើអាជីវកម្មជាក្រុមនៅតាមជនបទឱ្យទទួលបានជោគជ័យ គឺជាកិច្ចការមួយលំបាក ដោយសារស្ថានភាពរស់នៅ ចំណេះដឹង និងបទពិសោធន៍នៃការរកស៊ីរួមគ្នា របស់កសិករនាពេលបច្ចុប្បន្ននៅមានកំរិតនៅឡើយ។ ឯកសារនេះ ត្រូវបានរៀបចំឡើងដើម្បីជួយសម្រួលកិច្ចដំណើរការ និងគ្រប់គ្រងក្រុមមានប្រសិទ្ធភាព តាមរយៈការកសាងសមត្ថភាពសមាជិកក្រុម លើផ្នែក កសាងក្រុម ការប្រាស្រ័យទាក់ទង ការដឹកនាំក្រុម ក៏ដូចជាស្តីពី គោលគំនិតគ្រឹះនៃការចាប់ផ្តើម និងគ្រប់គ្រងអាជីវកម្មជាក្រុម។ វាក៏អាចជា ឯកសារប្រឹក្សាយោបល់ស្តីពី កិច្ចការជំនួញរបស់ក្រុមកសិករដែលចាប់ផ្តើមអាជីវកម្មរួមគ្នា នៅតាមជនបទ។

យើងខ្ញុំសូមស្វាគមន៍ចំពោះការកែលម្អ និង ការផ្តល់យោបល់នានាដើម្បីជាកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងនូវគុណភាពនៃឯកសារ នេះក្នុងគោលបំណងចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ តាមរយៈការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា ជាពិសេស កសិករនៅតាមជនបទ។

ការអនុវត្តន៍កម្មវិធីធ្វើបង្ហាញ ស្តីពី *ផលិតកម្មពូជស្រូវសម្រាប់លក់ជាក្រុម* នេះ អាចដំណើរការបានដោយសារមានការគាំទ្រពីថ្នាក់ដឹកនាំគម្រោង និង ក្រុមទីប្រឹក្សាគម្រោង TSTD និង ពីមន្ទីរកសិកម្មខេត្ត ទាំងបួន។

**អ្នករៀបរៀង:**

**លោក សំ សំណាង** អ្នកជំនាញផ្នែកក្សេត្រសាស្ត្រ / បន្លែ របស់គម្រោង TSTD

អ៊ីម៉ែល : Samnang_news@yahoo.com

## កែសម្រួលដោយ

**លោក លីវ លាងហ៊ី** អ្នកជំនាញផ្នែកផ្សព្វផ្សាយ និងបច្ចេកវិទ្យារបស់គម្រោង TSTD

អ៊ីម៉ែល: livleanghy@gmail.com

# មេរៀនទី១ ការបង្កើត និង កសាងក្រុមការងារ

## ១. សេចក្តីផ្តើម

ជាទូទៅក្រុមការងារ ឬ ក្រុមសហគមន៍មូលដ្ឋានមួយ ត្រូវបានរៀបចំឡើង តាមរយៈការប្រជុំឯកភាពគ្នាក្រោមគំនិតផ្តួចផ្តើមដោយសហគមន៍ផ្ទាល់ ឬ ក្រុមការងារ ដែលមានបំណងចូលរួមនៅក្នុងការងារអភិវឌ្ឍន៍ ឬក៏ដោយអាជ្ញាធរដែនដី។ ដើម្បីផ្តល់ភាពងាយស្រួលដល់ការអនុវត្តន៍ការងារ និង ជាប្រយោជន៍ដល់ការបង្កើតក្រុមឱ្យក្លាយជាក្រុមស្របច្បាប់នោះ ការរៀបចំរចនាសម្ព័ន្ធ គឺជាជំហានសំខាន់បំផុត នៅក្នុងដំណើរការគ្រប់គ្រង និងការងារជាក្រុម។

នៅក្នុងការរៀបចំរចនាសម្ព័នក្រុមនេះ មានវិធីជាច្រើនដែលបានប្រើដូចជា ការចាត់តាំង,ការបោះឆ្នោត និងការស្ម័គ្រចិត្ត ជាដើម។ ប៉ុន្តែនៅប៉ុន្មានទសវត្សចុងក្រោយនេះ ការរៀបចំរចនាសម្ព័ន្ធរយៈការបោះឆ្នោត ជាវិធី មានប្រជាប្រិយ និង មានប្រសិទ្ធភាព ដែលត្រូវបានគេប្រើ។

ក្រោយពីការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធរួចហើយ ជាទូទៅ ការទទួលស្គាល់ ពីអាជ្ញាធរដែនដី ដូចជាឃុំ និង មន្ទីរពាក់ព័ន្ធ ជាកត្តាចាំបាច់មួយ ដែលធ្វើឱ្យក្រុមក្លាយទៅជាក្រុមស្របច្បាប់នៅក្នុងកំរិតថ្នាក់មូលដ្ឋាន។

ការបង្កើតក្រុម អាចសំរេចបានដោយងាយស្រួល បើមានការគាំទ្រពីសំណាក់អាជ្ញាធរ ប៉ុន្តែប្រការដែលលំបាកគឺការថែរក្សា និង ជំរុញឱ្យក្រុមនេះក្លាយជាក្រុម ដែលមានសក្តានុពល និង រឹងមាំ និង មាននិរន្តរ៍ភាពលើការងារ ។ យន្តការជាច្រើនត្រូវបានធ្វើឡើង ដូចជាការរៀបចំតួនាទីភារកិច្ច ការពង្រឹងសមត្ថភាព ការគាំទ្រទាំងស្មារតី និង ថវិកា...... ជាដើម។ បទពិសោធន៍ជាច្រើនត្រូវបានបង្ហាញ និង លើកឡើង ដើម្បីជាការរៀនសូត្រនៅក្នុងការពង្រឹងក្រុមការងារនេះ។

ដើម្បីឱ្យកាន់តែយល់ច្បាស់ និង ចូលរួមចំណែកនៅក្នុងការពង្រឹងសមត្ថភាពក្រុមសហគមន៍មូលដ្ឋាន មេរៀននេះ នឹងជួយមួយចំណែកដល់ការបង្កើននូវសន្ទុះការងាររបស់ក្រុម។

## ២. និយមន័យក្រុម

- **ក្រុម (Group) :** ជា *ទំនាក់ទំនងបឋម* (រវាងបុគ្គល) សំដៅចែកចាយពត៌មាន និងធ្វើការសំរេចចិត្តដើម្បីជួយដល់មនុស្សម្នាក់ៗ ឱ្យអនុវត្តការងារទៅតាមភារៈកិច្ចទទួលខុសត្រូវរបស់គេ ដាច់ដោយឡែករៀងៗខ្លួន។

- **ក្រុមការងារ (Team):** គឺជាក្រុមមនុស្ស ដែលសមាជិកបុគ្គលិកម្នាក់ៗខិតខំប្រឹងប្រែងរួមគ្នាដើម្បីសំរេចលទ្ធផលការងារ បានល្អប្រសើរ ជាជាងគ្រាន់តែទាក់ទងស្វែងរកការចូលរួមយោបល់ពីបុគ្គលិកម្នាក់ៗ។